**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-Jun-2015, 16:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ** អមដោយឧបសម្ពន្ធពីរ (សាធារណៈ១ សម្ងាត់១)

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៤ របស់ នួន ជា ស្នើសុំឲ្យពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០១

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele MUMBA

**ចម្លងជូន:**
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Anta GUISSÉ
លោក Arthur VERCKEN

# I. សេចក្តីផ្តើម

1. នៅពេលនេះ សហព្រះរាជអាជ្ញា សូមឆ្លើយតបទៅនឹងសំណើលើកទីបួនដែលស្នើសុំឱ្យពិចារណាលើភស្តុតាងបន្ថែម ដែលបានដាក់ដោយមេធាវីការពារក្តីរបស់ នួន ជា[1]។ មេធាវីការពារក្តីបានស្វែងរកឱ្យបានទទួលនូវការដកស្រង់ជ្រើសរើសពីសក្ខីកម្មក្នុងសវនាការលើសំណុំរឿង០០២/០២ របស់អតីតលេខាស្រុកត្រាំកក់ឈ្មោះ ពេជ្រ ជឹម ក៏ប៉ុន្តែបានរំលងចោលនូវសក្ខីកម្មសំខាន់បំផុតរបស់សាក្សីរូបនោះ ដែលបានបញ្ជាក់ថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីគោលនយោបាយមួយរបស់ បកក អំពីការផ្តោតគោលដៅទៅលើពួកទាហាន និងពួករដ្ឋការ លន់ នល់ នៅក្នុងរយៈពេលក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ផ្ទុយទៅវិញ សក្ខីកម្មថ្មីដែលបានស្នើផ្តល់ដោយមេធាវីការពារក្តីមិនធ្វើឱ្យជាប់ទាក់ទងគ្នាទៅនឹងអំឡុងពេលដែលពួកទាហាន និងពួករដ្ឋការ លន់ នល់ ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃទេ ដូច្នេះហើយ មិនអាចជាកត្តាកំណត់នាំឱ្យសម្រេចបាននូវសាលក្រមនោះទេ។

2. អង្គជំនុំជម្រះតុលាការកំពូល "អជតក" មិនអាចពិចារណាដោយការញែកចេញពីគ្នា លើសក្ខីកម្មរបស់សាក្សីរូបនេះ លើសេចក្តីថ្លែងថ្មីៗដទៃទៀតដែលបានស្នើដោយមេធាវីការពារក្តី និងលើ សក្ខីកម្មនាពេលខាងមុខរបស់សាក្សីថ្មីៗ ដែលបានដាក់កាលវិភាគនៅដើមខែកក្កដា ឆ្នាំ២០១៥ នេះបានទេ។ បើសិនជាអង្គជំនុំជម្រះនេះធ្វើការស្តាប់ភស្តុតាងនៅលើបញ្ហាស្តីពីគោលនយោបាយរបស់ បកក ចំពោះពួកទាហាន និងពួកមន្ត្រីរដ្ឋការ លន់ នល់ ជាថ្មីឡើងវិញ ដោយមានមូលដ្ឋាននៅលើសក្ខីកម្មថ្មីដែលបានមកពីសវនាការលើសំណុំរឿង០០២/០២ ឬបានមកពីកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ ឬ០០៤នោះ ភស្តុតាងថ្មីបែបដូច្នោះ ត្រូវតែបានធ្វើការវាយតម្លៃជាមួយនឹង (ក) សក្ខីកម្មទូលំទូលាយរបស់សាក្សី និងឯកសារចំនួនរាប់រយដែលបានទទួលយកនៅក្នុងអំឡុងពេលនៃសវនាការលើសំណុំរឿង០០២/០១ ស្តីពីប្រធានបទនោះ, និង (ខ) ភស្តុតាងថ្មីសំខាន់ៗប្រហែលគ្នាដទៃទៀតដែលទាក់ទងទៅនឹងគោលនយោបាយ ដែលធ្លាប់លើកឡើងនៅក្នុងដំណើរការសវនាការនៃសំណុំរឿង០០២/០២ និងក្នុងកិច្ចស៊ើបសួរលើសំណុំរឿង០០៣ និង០០៤ ដែលបានគាំទ្រយ៉ាងពេញទំហឹងដល់ការយល់ឃើញរបស់អង្គជំនុំម្រះសាលាដំបូង នៅក្នុងសាលក្រមនៃសំណុំរឿង០០២/០១។

[1] **F2/6** សំណើលើកទីបួនរបស់ នួន ជា ស្នើសុំឱ្យពិចារណាលើភស្តុតាងបន្ថែម ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០១, ១៥ មិថុនា ២០១៥ ("សំណើលើកទីបួន ស្តីពីភស្តុតាងបន្ថែម")។

3. អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋាន ដោយមានអមទៅជាមួយនឹងចម្លើយតបនេះនូវឧបសម្ពន្ធនានាដែលសង្ខេបភស្តុតាងថ្មីពីក្នុងសំណុំរឿង០០២/០២ ស្តីពីប្រធានបទនេះ (**ឧបសម្ពន្ធ ក**) និងពីក្នុងសំណុំរឿង០០៣ និង០០៤ (**ឧបសម្ពន្ធសម្ងាត់ ខ**)។ អាណត្តិនៃផលប្រយោជន៍នៃយុត្តិធម៌ដែលមេធាវីការពារក្តីបានស្នើសុំសម្រាប់ភស្តុតាងបន្ថែម និងសក្ខីកម្មរបស់សាក្សីចំនួនបីរូបដែលនឹងត្រូវបានស្តាប់នាពេលខាងមុខដោយអង្គជំនុំជម្រះនេះ គួរត្រូវបានពិចារណានៅក្នុងបរិបទមួយត្រឹមត្រូវ និងពេញលេញ ដែលនៅក្នុងករណីណាមួយក៏ដោយ ត្រូវមានលក្ខណៈច្បាស់លាស់ ដែលថាភស្តុតាងថ្មីដែលមានកើតឡើងចាប់តាំងពីនៅក្នុងសវនាការលើសំណុំរឿង០០២/០១ មិនមានការប្រែប្រួលឡើយ ហើយដែលតាមពិតទៅ នឹងមានការគាំទ្របន្ថែមទៀតដល់ការផ្តន្ទាទោសជនជាប់ចោទ។

## II. សក្ខីកម្មរបស់ ពេជ្រ ជឹម និង SCW-4 ដែលគេបានស្នើផ្តល់នោះ មិនអាចជាកត្តាកំណត់មួយដែលអាចធ្វើឲ្យមានការប្រែប្រួលដល់សាលក្រមលើសំណុំរឿង០០២/០១ឡើយ

4. នៅក្នុងការអនុវត្តវិធាន១០៨(៧) នៃវិធានផ្ទៃក្នុង អជតក ធ្លាប់បានបង្កើតបទដ្ឋានដែលមានបីលក្ខខណ្ឌ ដោយអនុលោមទៅតាមអ្វីដែលត្រូវបានបង្កើតឡើង សម្រាប់ភស្តុតាងថ្មីដែលបាន ស្នើឲ្យទទួលយកសម្រាប់បណ្តឹងសាទុក្ខ៖ (i) ពុំអាចរកបាននៅពេលជំនុំជម្រះ ទោះជាបានអនុវត្ត ដោយការប្រឹងប្រែងហ្មត់ចត់ក្តី, (ii) អាចជាកត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេច ដែលទទួលរងបណ្តឹងសាទុក្ខ, និង (iii) ទាក់ទងទៅនឹងការយល់ឃើញជាក់លាក់អំពីអង្គហេតុ របស់អង្គជំនុំជម្រះសាលាដំបូង[2]។

5. វិធាននេះ បានបង្កើតនូវបទដ្ឋានតឹងតែងមួយក្នុងការទទួលយកនូវភស្តុតាងថ្មីលើបណ្តឹងសាទុក្ខ។ មិនត្រឹមគ្រាន់តែមានភាពពាក់ព័ន្ធគ្នាទេ ភស្តុតាងនោះត្រូវតែមានទម្ងន់បែបដូច្នេះ ហើយភាពសំខាន់ដែលអាចមាននោះ ត្រូវតែជា “កត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅពេលសវនាការ”។ បទដ្ឋានតឹងតែងមួយបែបដូច្នេះ គឺចាំបាច់ណាស់ដើម្បីចៀសវាងកុំឲ្យបណ្តឹងសាទុក្ខមានការខូចខាតនៅក្នុងសវនាការលើកទីពីរ ដោយបន្លាយកិច្ចដំណើរការនីតិវិធីមិនសមស្រប និងធ្វើឲ្យមាន

[2] **F2/5** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, ២៩ ឧសភា ២០១៥, ត្រង់កថាខណ្ឌ ១៦។

ជាបណ្តឹងវិវាទមួយដែលមិនមានប្រសិទ្ធិភាព[3]។ ចំពោះហេតុផលនានាដូចដែលបានជម្រាបខាងលើនេះ សក្ខីកម្មរបស់ ពេជ្រ ជឹម ដែលបានស្នើផ្តល់នេះ មិនត្រូវតាមបទដ្ឋានទាំងនេះទេ ដោយហេតុថាវាមិនមែនជាកត្តាកំណត់នាំឱ្យសម្រេចបាននូវសាលក្រមនោះទេ។

6. ជាដំបូង សហព្រះរាជអាជ្ញាសង្កេតឃើញថា មេធាវីការពារក្តីបានស្វែងរកការឱ្យបានទទួលនូវការដកស្រង់ដែលមានកម្រិត ចេញពីប្រតិចារឹកពីរក្នុងចំណោមប្រតិចារឹកបួនរបស់អតីតលេខាស្រុកត្រាំកក់ឈ្មោះ ពេជ្រ ជឹម ពីក្នុងសក្ខីកម្មសវនាការលើសំណុំរឿង០០២/០២ ដោយបានរំលងចោលនូវសក្ខីកម្មក្នុងអំឡុងពេលពេញមួយថ្ងៃដំបូងរបស់សាក្សីរូបនោះ ដែលនៅក្នុងនោះគាត់បានផ្តល់ ភស្តុតាងដាក់បន្ទុកសំខាន់ស្តីពីប្រធានបទដូចគ្នា។ ដោយឡែក មេធាវីការពារក្តីបានស្វែងរកឱ្យ បានទទួលសក្ខីកម្មរបស់ ពេជ្រ ជឹម ដែលបានផ្តល់ឱ្យ បន្ទាប់ពីក្រុមមេធាវីការពារក្តីរបស់ នួន ជា បានអានឱ្យគាត់ស្តាប់នូវចម្លើយរបស់ SCW-4 ពាក់ព័ន្ធនឹងការប្រជុំមួយដែល តាម៉ុក មានគោលបំណងណែនាំអំពីពួកអតីតទាហាន លន់ នល់ ក្នុងលំដាប់សក្តិជាក់លាក់មួយចំនួន ហាមមិនឱ្យប៉ះពាល់ទេ។ ជាប្រតិកម្មទៅនឹងចម្លើយរបស់ SCW-4 ពេជ្រ ជឹម បានផ្តល់សក្ខីកម្មថា គាត់អាចនឹងមានវត្តមាននៅពេលប្រជុំនោះ និងបានឮសេចក្តីណែនាំនោះ។ យ៉ាងណាក៏ដោយ កិច្ចប្រជុំជាមួយ តាម៉ុក ដែលត្រូវបានរៀបរាប់ដោយ SCW-4 ហើយដែលត្រូវបានបញ្ជាក់ដោយ ពេជ្រ ជឹម នេះបានកើតឡើងយ៉ាងហោចណាស់ក៏ "ពីរ-បីខែ" ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែរ[4] គឺ

---

[3] *រដ្ឋអាជ្ញា ទល់នឹង Kupreškić និងគូកន*, សំណុំរឿងលេខ IT-95-16-A, សេចក្តីសម្រេចលើញត្តិរបស់ Drago Josipović, Zoran Kupreškić និង Vlatko Kupreškić ស្នើសុំឱ្យទទួលយកភស្តុតាងបន្ថែម ដោយអនុលោមតាមវិធាន១១៥ និងសុំឱ្យចេញសច្ចទស្សន៍តុលាការ (Judicial Notice) ដោយអនុលោមតាមវិធាន៩៤(ខ), ៨ ឧសភា ២០០១ ត្រង់កថាខណ្ឌ ៣។

[4] **E305/13.23.405** បទសម្ភាសន៍ជាមួយ SCW-4 ដោយ DC-Cam, ២០ មេសា ២០១១, ត្រង់ ENG 01098761 ("តាម៉ុក ប្រកាសនៅភ្នំត្រែ ចាប់ពីសក្តិ៥ ឡើងទៅ មិនត្រូវប៉ះពាល់ដល់ជីវិតទេ។ គាត់មិនបានបញ្ជាក់ភ្លាមក្រោយពីរំដោះឡើយ។ គាត់រង់ចាំពីរ បីខែ រហូតដល់ក្រោយដែលថាបានធ្វើការប្រកាសនេះ។ **E127/7.1.8** កំណត់ហេតុស្តាប់ចម្លើយសាក្សី SCW-4 ដោយ កសចស, ១៧ កុម្ភៈ ២០១៣, ត្រង់ A9 ("ក្រោយឆ្នាំ១៩៧៥ មានការប្រជុំម្តងទៀត នៅទីរួមខេត្តតាកែវ ដោយមាន តាម៉ុក ចូលរួម ហើយឈ្មោះ សោម ដែលជាគណៈតំបន់១៣ បានធ្វើការប្រកាសថា ទាហានរបប លន់ នល់ ពីសក្តិមួយ ដល់សក្តិប្រាំ មិនត្រូវប៉ះពាល់")។ **E1/292.1** ប្រតិចារឹក, ២៤ មេសា ២០១៥, ពេជ្រ ជឹម, ត្រង់ 09.45.12 [ដោយបានផ្តល់សក្ខីកម្មពីជំនឿរបស់គាត់ថាការប្រជុំជាមួយ តាម៉ុក បានធ្វើឡើងនៅបន្ទាប់ពីចុងខែឧសភា ឆ្នាំ១៩៧៥ ទោះបីជាគាត់បានទទួលសារភាពផងដែរថា គាត់ "ឆ្លើយក៏វង្វេងដែរ ខ្លះត្រូវ អាចខ្ញុំឆ្លើយខុស" ក៏ដោយ អំពីការប្រជុំបែបដូច្នោះ]។ សហព្រះរាជអាជ្ញាកត់សម្គាល់ពីភាពមិនខ្ជាប់ខ្ជួនសំខាន់ទាំងឡាយរវាងសេចក្តីថ្លែងដំបូងរបស់ SCW-4 ទៅកាន់ DC-Cam នៅខែមេសា ឆ្នាំ២០១១ និងអ្វីដែលគាត់បានប្រាប់ទៅអ្នកស៊ើបអង្កេតនៃ កសចស នៅខែកុម្ភៈ ឆ្នាំ២០១៣ ដែលទាំងនេះសុទ្ធតែជាបញ្ហាដែលត្រូវរុករកឱ្យបានជាក់ស្តែងពីសាក្សីរូបនោះ នៅក្នុងអំឡុងពេលនៃសក្ខីកម្មរបស់គាត់នាពេលខាងមុខនេះ។

ក្រោយពេលដែល បកក បានអនុវត្តនូវការរៀបចំសម្លាប់ពួកនាយទាហាន និងពួកមន្ត្រីរដ្ឋការ លន់ នល់ នៅទួលពោធិ៍ជ្រៃ នៅស្រុកត្រាំកក់ និងនៅតាមទីកន្លែងដទៃទៀតពាសពេញផ្ទៃប្រទេស រួចជាស្រេចទៅហើយ។

7. សំណើរបស់មេធាវីការពារក្តីលុបចោលនូវសក្ខីកម្មសវនាការសំខាន់បំផុត ដែលបានផ្តល់ឲ្យដោយសាក្សី ពេជ្រ ជឹម លើប្រធានបទនេះ ជាសក្ខីកម្មដែលទាក់ទងនឹងការណែនាំពីថ្នាក់ដឹកនាំ បកក លើការបោសសំអាតទាហាន លន នល់ ដែលត្រូវបានអនុវត្តភ្លាមៗក្នុងរយៈកាលក្រោយពេលរំដោះ។ សាក្សីសវនាការមុននេះ (រៀល សន ដែលជាអតីតអនុប្រធានមន្ទីរពេទ្យស្រុកត្រាំកក់) បានផ្តល់សក្ខីកម្មថាបានចូលរួមក្នុងការប្រជុំចំនួនពីរ មួយមុនពេលជម្លៀស និងមួយទៀតក្រោយពេលជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ដែលក្នុងការប្រជុំនោះ ពេជ្រ ជឹម បានណែនាំថា មន្ត្រីរដ្ឋការ លន់ នល់ ត្រូវតែកំណត់អត្តសញ្ញាណ និងបោសសំអាត[5]។ នៅពេលដែលត្រូវបានតទល់ជាមួយនឹងសក្ខីកម្មនេះនៅក្នុងសវនាការសំណុំរឿងលេខ០០២/០២ ពេជ្រ ជឹម បាននិយាយថា៖ "នោះជាផែនការរបស់ថ្នាក់លើ ហើយយើងបានផ្សព្វផ្សាយផែនការនោះ"[6]។ គាត់បានផ្តល់សក្ខីកម្មបន្តទៀតថា៖

> កាលនោះ ខុម [*កូនស្រីរបស់ តាម៉ុក បន្ទាប់មកជាលេខាស្រុកត្រាំកក់*] យកផែនការហ្នឹងពីតំបន់មកមកផ្សាយអ៊ីចឹង។ ផ្សាយប៉ុនយើងផ្សាយប្រាប់ ខុម។ ខ្ញុំបានចូលរួម។ តែមិនមានឃើញបោសសំអាត មានឃើញហៅនរណាឡើយ សួរបញ្ជាក់ថាអស់ ឬនៅ? ថាអស់ហើយ មានអ្នកណាមាននៅ យកអស់ហើយ គេយកថ្ងៃ១៧ មេសា អស់ហើយតាមផ្លូវទៅខេត្ត។ និយាយត្រង់អ៊ីចឹង មាន

[5] **E3/5511** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀល សន ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៩ ត្រង់ចម្លើយ A9 ["មុនពេលដែលគេជម្លៀសប្រជាជន [ពីភ្នំពេញ] មកតំបន់នេះ ប្រធានស្រុក ប្រធានឃុំ ប្រធានភូមិ និងសមាជិកអង្គភាពត្រូវបានគេអញ្ជើញទៅចូលរួមក្នុងសន្និសីទ។ អ្នកចូលរួមក្នុងអង្គប្រជុំត្រូវបានគេប្រាប់ថា តើប្រជាជនប្រភេទណាខ្លះដែលត្រូវកម្ទេច [...] ប្រជាជនដែលគេកំណត់ថាត្រូវកម្ទេចនោះ នៅផ្នែកយោធា ដែលមានតំណែងចាប់ពីអាក់ស៊ីដង់ឡើងទៅ។ ហើយចំពោះអ្នកធ្វើការនៅក្នុងផ្នែករដ្ឋបាល គឺចាប់ពីជំទប់ទី១ ឡើងទៅ"]។ **E1/278.1** ប្រតិចារឹកសវនាការ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ រៀល សន នៅម៉ោង ១១.១៧.១២ ដល់ ១១.២១.៣៩, ១៣.៣២.១៥។ **E1/279.1** ប្រតិចារឹកសវនាការ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ រៀល សន នៅម៉ោង ១៥.០៥.០៣ ដល់ ១៥.១៨.១០ [សាក្សីបានចូលរួមក្នុងការប្រជុំចំនួនពីរ មួយមុនពេលជម្លៀស និងមួយទៀតក្រោយពេលជម្លៀសប្រជាជន។ នៅក្នុងការប្រជុំលើកទីពីរ ពេជ្រ ជឹម បានណែនាំមេភូមិ និងមេឃុំឲ្យស្រាវជ្រាវរកថាតើប្រជាជនជម្លៀសជាមន្ត្រីរដ្ឋការ លន់ នល់ ដែលមានបណ្តាស័ក្តិ ឬជាមន្ត្រីរដ្ឋការស៊ីវិល ប្រសិនបើមាន ពួកគេត្រូវបោសសម្អាត]។

[6] **E1/291.1** ប្រតិចារឹកសវនាការ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ពេជ្រ ជឹម នៅម៉ោង ១១:០០:៣៧។

នៅណាទៀត។ អ៊ីចឹងរកមើលទៅក្រែងមាន [...] គិតឃើញថា បើគេប្រមូលមែន ពួកហ្នឹងវាអស់អនាគតហើយ។ ជោគវាសនាវាអន្តរាយ[7]។

8. សក្ខីកម្មរបស់ SCW-4 និង ពេជ្រ ជឹម អំពីការណែនាំរបស់ តាម៉ុក ដែលបានលើកឡើងនោះ ត្រូវវាយតម្លៃធៀបទៅនឹងភស្តុតាងដែលមានស្រាប់ផ្សេងទៀត ដែលគាំទ្រសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងគោលនយោបាយរបស់ បកក ក្នុងការផ្តោតលើអតីតទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ ដែលត្រូវបានអនុវត្តភ្លាមៗក្នុងសប្តាហ៍ក្រោយថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥។ ឧទាហរណ៍ សមាជិកគណៈអចិន្ត្រៃយ៍ អៀង សារី បានទទួលស្គាល់ថា ប្រហែលជាថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ថ្នាក់ដឹកនាំ បកក បានសម្រេចឱ្យពង្រីកការសម្លាប់ទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ បន្តដល់ថ្នាក់ក្រោមទៀតលើសពី "ពួកមហាក្បត់" ទាំង ៧នាក់ ដែលត្រូវបានប្រកាសឱ្យសម្លាប់ក្នុងសេចក្តីថ្លែងជាសាធារណៈដែលបានចេញដោយ ខៀវ សំផន[8]។ កម្មាភិបាល បកក ផ្សេងទៀត បញ្ជាក់ថា ថ្នាក់ដឹកនាំបក្សបានផ្តល់ការណែនាំក្នុងរយៈកាលនោះឱ្យសម្លាប់មន្ត្រីរដ្ឋការ និងទាហានមានបណ្តាស័ក្តិខ្ពស់នៃរបប លន់ នល់ ទាំងអស់[9]។ សាក្សីទាំងឡាយក៏បាន

---

[7] **E1/291.1** ប្រតិចារឹកសវនាការ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ពេជ្រ ជឹម នៅម៉ោង ១១.០៥.១៦ ដល់ ១១.០៩.៤១ (សង្កត់ន័យ)។

[8] **E3/89** អត្ថបទសម្ភាសន៍ជាមួយ អៀង សារី ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ ត្រង់ ERN ជាភាសាអង់គ្លេស 00417606។ **E3/532** បទសម្ភាសន៍ជាមួយ អៀង សារី ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ ត្រង់ ERN ជាភាសាអង់គ្លេស 00003665។ **E3/117** សារព័ត៌មាន FBIS មានចំណងជើងថា *ខៀវ សំផន ធ្វើជាអធិបតីសម័យប្រជុំសមាជរបស់រណៈសិរ្សរួបរួមជាតិនៃកម្ពុជា សេចក្តីថ្លែងការណ៍ដែលត្រូវបានផ្សព្វផ្សាយ* ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ ត្រង់ ERN ជាភាសាអង់គ្លេស 00166772, ជាភាសាខ្មែរ 00242309, ជាភាសាបារាំង 00281432។

[9] សូមមើល ឧទាហរណ៍ **E319/19.3.125** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [ឈ្មោះត្រូវបានកោសលុប] ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ត្រង់ ERN ជាភាសាអង់គ្លេស 01031927-28 [សមាជិកគណៈឃុំសន្លុង ជាផ្នែកនៃស្រុកអង្គរជ័យ តំបន់១៣ នៃភូមិភាគនិរតី ដែលបានរៀបរាប់ពីរបៀបដែលអតីតទាហាន លន់ នល់ ពាក់ស័ក្តិមួយ ឬខ្ពស់ជាងនេះត្រូវសម្លាប់ចោល តាមបញ្ជារបស់ថ្នាក់លើ មួយឬពីរសប្តាហ៍ក្រោយការដួលរលំនៃរបបចាស់]។ **E3/5649** បទសម្ភាសន៍ DC-Cam ជាមួយ [ឈ្មោះត្រូវបានកោសលុប] ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៤ ត្រង់ ERN ជាភាសាអង់គ្លេស 00885243, 00885246-47។ **E3/387** បទសម្ភាសន៍ជាមួយ អ៊ុក ប៊ុនឈឿន ថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៨០ ត្រង់ ERN ជាភាសាអង់គ្លេស 00350205 [និយាយថា ថ្នាក់ដឹកនាំ បកក បានចេញគោលនយោបាយមួយក្នុងខែមេសា ឆ្នាំ១៩៧៥ ឱ្យ "បោសសម្អាតសមាសភាពក្នុងរដ្ឋការ លន់ នល់" ដោយបញ្ជាក់ថា "ស៊ីវិលហ្នឹងវាចាប់ឱ្យបោសសម្អាតពីមេឃុំឡើងរហូតដល់ថ្នាក់លើទាំងអស់ ទាហានវាចាប់ផ្តើមឱ្យបោសសម្អាតពីនាយទាហានស័ក្តិមួយឡើងទៅរហូតដល់ឧត្តមសេនីយ៍"]។ **E319/12.3.2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ហឿន ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ ត្រង់ចម្លើយ A22-A24, A91 & A254-A255 [សក្ខីកម្មរបស់អតីតមេឃុំជាងទង និងជាអតីតសមាជិកគណៈស្រុកត្រាំកក់ និយាយថា៖ "នៅពេលដែលចាប់ផ្តើមរបបខ្មែរក្រហមភ្លាម គឺចាប់ផ្តើមធ្វើប្រវត្តិរូប ថាអ្នកណាខ្លះធ្លាប់ធ្វើជាគ្រូ

បញ្ជាក់ផងដែរថា តាម៉ុក មានវត្តមាននៅពេលដែលទាហាន លន់ នល់ ត្រូវបានប្រមូលផ្តុំ និងយកទៅសម្លាប់នៅព្រលានយន្តហោះពោធិ៍ចិនតុង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[10] និងនៅវត្តចំប៉ា ក្នុងស្រុកត្រាំកក់ ក្នុងរយៈកាលភ្លាមៗបន្ទាប់ពីប្រជាជនជម្លៀស ១៧មេសា បានមកដល់ ហើយត្រូវបានប្រមូលផ្តុំនៅទីតាំងនោះ[11]។ ការសម្លាប់ទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ ដែលបានរៀបចំឡើងស្រដៀងគ្នានេះដែរ បានកើតឡើងនៅទីកន្លែងផ្សេងៗនៅទូទាំងប្រទេសកម្ពុជានៅថ្ងៃ និងសប្តាហ៍ភ្លាមៗក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥[12]។ សក្ខីកម្មរបស់ SCW-4 និង ពេជ្រ ជឹម

---

បង្រៀន អ្នកណាជាប៉ូលិស ឬក៏ជាមន្ត្រីរាជការនៅក្នុងរបប លន់ នល់ បន្ទាប់មកបញ្ជូនប្រវត្តិរូបទាំងអស់ទៅខាងលើ។ នេះគឺជាបញ្ជាពីខាងលើមកឲ្យខ្ញុំធ្វើដូច្នេះ។ [...] ក្រោយបញ្ជូនប្រវត្តិរូបទៅលើហើយ ខាងលើបានស្រង់ឈ្មោះអ្នកទាំងអស់នោះមកឲ្យខ្ញុំ។ បន្ទាប់មកខ្ញុំបញ្ជាឲ្យគេដើរចាប់អ្នកទាំងអស់នោះ រួចបញ្ជូនទៅខាងលើវិញ។”

[10] ឧបសម្ព័ន្ធសម្ងាត់ ខ លេខ ៩៤ __ សេចក្តីសង្ខេបកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ កសចស ជាមួយសាក្សី **E319/23.3.42** [ឈ្មោះត្រូវបានកោសលុប] ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៤ ត្រង់ចម្លើយ A14-A37 [កម្មាភិបាលពីកងពលលេខ១ នៃកងទ័ពភូមិភាគនិរតី រៀបរាប់ពីរបៀបដែលទាហានថ្នាក់ខ្ពស់មួយក្រុមធំ និងអ្នកបើកយន្តហោះរបប លន់ នល់ ត្រូវបានប្រមូលផ្តុំ និងយកចេញភ្លាមៗទៅកម្ទេចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ត្រង់ព្រលានយន្តហោះពោធិ៍ចិនតុង ដោយនិយាយថា តាម៉ុក, មាស មុត, និង ស៊ូ ម៉េត មានវត្តមាន ហើយថាគឺ តាម៉ុក ជាអ្នកបញ្ជាថាទាហាន លន់ នល់ ត្រូវយកទៅកម្ទេច]។

[11] **E3/5153** កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ កសចស ជាមួយសាក្សី កែវ ចាន់តារ៉ា ថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨ ត្រង់ ERN ជាភាសាអង់គ្លេស 00205090, ជាភាសាខ្មែរ 00172044, ជាភាសាបារាំង 00205095 [ប្រជាជនជម្លៀសបានប្រមូលផ្តុំនៅវត្តចំប៉ា ក្នុងស្រុកត្រាំកក់ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ភាគច្រើននៃអ្នកទាំងនោះត្រូវបានយកទៅសម្លាប់នៅក្រាំងតាចាន់ ក្របីព្រៃ មន្ទីរ១៦០ និងមន្ទីរ២០៤]។ **E1/255.1** ប្រតិចារឹកសវនាការ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ កែវ ចាន់តារ៉ា នៅម៉ោង ១១.០៩.២៨ ដល់ ១១.១១.៤៥, ១៣.៤៦.១៦ ដល់ ១៣.៤៩.២៤ [សាក្សីដែលរស់នៅជិតវត្តចំប៉ា បានផ្តល់សក្ខីកម្មថា គាត់បានឃើញ “ប្រជាជនជម្លៀសរាប់ពាន់នាក់” ប្រមូលផ្តុំនៅទីនោះ ហើយគាត់ក៏បានឃើញ តាម៉ុក នៅទីនោះដែរ ហើយទាហាន លន់ នល់ ត្រូវបានយកទៅកាន់ទីតាំងមួយនៅព្រៃក្តួច ហៅថា “មន្ទីរ២០៤”]។ **E319.1.32** កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ កសចស ជាមួយសាក្សី អ៊ុល ហឿន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ត្រង់ចម្លើយ A113 [រៀបរាប់អំពីរបៀបដែល “មនុស្សត្រូវបានជម្លៀសចេញពីក្រុងភ្នំពេញទៅកាន់វត្តចំប៉ាលើក” ដែលជាកន្លែងខ្មែរក្រហមកំណត់អត្តសញ្ញាណ ប្រមូលផ្តុំ និងយកចេញនូវ “ទាហានពាក់ស័ក្តិ” ដូចជា “ស័ក្តិមួយ និងស័ក្តិពីរ [ទាល់តែ] នៅសល់តែប្រជាជនធម្មតា”]។ **E1/290.1** ប្រតិចារឹកសវនាការ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ពេជ្រ ជឹម នៅម៉ោង ១០.៥៩.១០ [បានបញ្ជាក់ថា តាម៉ុក មានវត្តមាននៅពេលដែលប្រជាជនជម្លៀសត្រូវបានប្រមូលផ្តុំនៅវត្តចំប៉ា]។ **E3/2048** សេចក្តីរាយការណ៍ជូនអង្គការស្រុកត្រាំកក់ ពីឃុំជាងទង ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ ត្រង់ ERN ជាភាសាខ្មែរ 00079089, ជាភាសាអង់គ្លេស 00276562-63, ជាភាសាបារាំង 00611659 [ឪពុកវាធ្វើចីផែនទី នៅតាកែវ ពេលយើងរំដោះចេញមកដក់វត្តចំប៉ា អ.ក យើងដកហូតឪពុកវានេះទៅ]។ **E3/2107** សៀវភៅកំណត់ត្រាគុកក្រាំងតាចាន់ ត្រង់ ERN ជាភាសាអង់គ្លេស 00290205-06, ជាភាសាខ្មែរ 00068050, ជាភាសាបារាំង 00655726 [កំណត់សម្គាល់ចំពោះអ្នកទោសឈ្មោះ ជួន សុវណ្ណៈ “ឪពុកធ្វើមេឃុំ អង្គការចាប់តាំងពីដល់វត្តចំប៉ា”]។

[12] សូមមើល *ឧទាហរណ៍* **D390** សេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៦៦ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ត្រង់កថាខណ្ឌ ១៧១-១៧២, ១៩៤-១៩៦, ១៩៨, ២២៦។ **E295/6/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល

ទាក់ទងនឹងការប្រជុំដែលបានធ្វើឡើងនៅប៉ុន្មានខែក្រោយការសម្លាប់ទាំងនេះ មិនធ្វើឲ្យថមថយ និងមិនអាចជា "កត្តាកំណត់" ដែលអាចផ្លាស់ប្តូរសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ។

9. សហព្រះរាជអាជ្ញាកត់សម្គាល់បន្ថែមទៀតថា សក្ខីកម្មរបស់ SCW-4 និង ពេជ្រ ជឹម អំពីការណែនាំរបស់ តាម៉ុក ដែលបានលើកឡើងថាមិនត្រូវប៉ះពាល់ដល់ទាហាន លន់ នល់ ក្នុងថ្នាក់ជាក់លាក់ណានោះ មិនរាំងស្ទះដល់ការត្រួតពិនិត្យនៅពេលដែលគេធ្វើការពិចារណាលើភស្តុតាងដែលមានស្រាប់ចំពោះអ្វីដែលបានកើតឡើងលើក្រុមនោះ ក្នុងអំឡុងពេលក្រោយមកទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ (គឺក្រោយពេលពាក់កណ្តាលឆ្នាំ១៩៧៥ ជាពេលដែលបានលើកឡើងអំពីការណែនាំពី តាម៉ុក)។ ឧទាហរណ៍ អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានផ្តល់សក្ខីកម្មថា នៅក្នុងអំឡុងនៃដើមសម័យកាលស-២១ ចាប់ពីចុងឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៦ ក្រុមអ្នកទោសធំបំផុតគឺមន្ត្រី និងទាហាន លន់ នល់[13] ហើយកំណត់ហេតុសហកាលពីមន្ទីរស-២១ បញ្ជាក់អះអាងថា ក្រុមអ្នកទោសធំដូច្នេះពិតជាត្រូវបានឃុំខ្លួន និងសម្លាប់នៅស-២១ ក្នុងចិរវេលានេះមែន[14]។ ប្រសិនបើ ប៉ុល ពត, នួន ជា និងតាម៉ុក ពិតជាបានណែនាំមិនឲ្យបង្កគ្រោះថ្នាក់ដល់មន្ត្រី និងទាហានលន់ នល់ ដែលមានបណ្តាសក្តិពិតប្រាកដមែននោះ ម្ល៉េះសមមន្ត្រីទាំងនោះមិនត្រូវបានគេចាប់ខ្លួន ឃុំខ្លួន និងសម្លាប់នៅមន្ទីរសន្តិសុខនេះ ដែលជាមន្ទីរសន្តិសុខរាយការណ៍ផ្ទាល់ទៅគណៈអចិន្ត្រៃយ៍របស់ បកក នោះឡើយ។

10. ស្រដៀងគ្នានេះ កំណត់ហេតុរបស់អ្នកនៅរស់រានមានជីវិតពីស្រុកត្រាំកក់ ពីចិរវេលាចាប់ពីខែមេសា ដល់ខែឧសភា ឆ្នាំ១៩៧៧ បានលើកយោងយ៉ាងច្បាស់អំពីការណែនាំពីស្រុក នៅក្នុងការ

---

របស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿងលេខ០០២/០១ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ កថាខណ្ឌ ២៩១-២៩៧, ៣០៩-៣១០។ សំណើសុំកែតម្រូវលើឯកសារលេខ **F17/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខសំណុំរឿងលេខ០០២/០១ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ កថាខណ្ឌ ៣៦៧-៣៧៦, ៣៨១-៣៨៣, ៣៨៥-៣៨៩។

[13] **E1/32.1** ប្រតិចារឹក, ១៥ មិថុនា ២០០៩, កាំង ហ្គេចអ៊ាវ ហៅ ឌុច, ទំព័រ៧ ត្រង់ 9.31.40។

[14] សូមមើល *ឧទាហរណ៍* ឯកសារលេខ **E3/1539** បញ្ជីសម្លាប់ស-២១ [បញ្ជីឈ្មោះទាហាន និងមន្ត្រីលន់ នល់ និងសមាជិកគ្រួសាររបស់ពួកគេចំនួន១៦២នាក់ដែលបានសម្លាប់ ឬស្លាប់ដោយសារជំងឺនៅស-២១ ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដោយមានបញ្ជាក់ឋានន្តរសក្តិ]។ ឯកសារលេខ **E3/3973** បញ្ជីសម្លាប់ស-២១, ត្រង់ ERN ជាភាសាអង់គ្លេស 00837571-81 [បញ្ជីឈ្មោះទាហានលន់ នល់ ២០៦នាក់ដែលបានជាប់ឃុំឃាំងនៅស-២១ ដោយមានបញ្ជាក់ឋានន្តរសក្តិ ថ្ងៃចាប់ខ្លួន និងថ្ងៃសម្លាប់]។

កំណត់អត្តសញ្ញាណ និងបោសសម្អាតមន្ត្រីមានបណ្ដាសក្តិរបស់លន់ នល់[15] ហើយកម្មាភិបាលភូមិភាគនិរតីដែលបានចាត់តាំងដោយប៉ុល ពត, នួន ជា និងតាម៉ុក ឲ្យធ្វើការបោសសម្អាតភូមិភាគកណ្ដាល(ឧត្តរចាស់) នៅក្នុងអំឡុងនៃថិរវេលាដូចគ្នានេះ បានថ្លែងថា ពួកគេបានទទួលការណែនាំពីថ្នាក់លើរបស់ខ្លួនដើម្បីកំណត់អត្តសញ្ញាណចាប់ខ្លួន និងសម្លាប់អតីតទាហាន លន់ នល់ នៅក្នុងស្រុករបស់ពួកគាត់[16]។ ជាងហាសិបភាគរយនៃអ្នកទោសដែលមានឯកសារនៅក្រាំងតាចាន់ ដែលជាមន្ទីរសន្តិសុខរបស់ស្រុកត្រាំកក់ គឺជាអតីតទាហាន មន្ត្រីរដ្ឋការ និងប៉ូលីសរបស់លន់ នល់[17]។ លេខាដើមរបស់ស្រុកត្រាំកក់គឺ យាយខុម កូនស្រីរបស់តាម៉ុក ហើយលេខាបន្តបន្ទាប់របស់ស្រុកនេះគឺ បងប្អូនថ្លៃប្រុស និងបងប្អូនជីដូនមួយរបស់តាម៉ុក។ បើតាមទ្រង់ទ្រាយនៃភស្តុតាងនេះ ការអះអាងរបស់សាក្សី SCW-4 និង ពេជ្រ ជឹម ដែលបានផ្ដល់ដោយមេធាវីការពារក្ដី មិនអាចជា "កត្តាកំណត់" ដែលអាចជំនះភស្តុតាងច្បាស់លាស់ និងលើសលប់ឡើយ ដោយហេតុថា អតីតទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ នៅតែជាក្រុមគោលដៅនៃការចាប់ និងសម្លាប់នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងនៅភូមិភាគនានាដែលតាម៉ុកទទួលខុសត្រូវផ្ទាល់ផងដែរ។

---

[15] **E3/2048** សេចក្តីរាយការណ៍ផ្ញើជូនអង្គការស្រុកត្រាំកក់ ពី ខឹម បឿន ប្រធានឃុំជាងទង, ៣០ មេសា ១៩៧៧, ត្រង់ ERN ជាភាសាខ្មែរ 00079089, ភាសាអង់គ្លេស 00276562-63, ភាសាបារាំង 00611659 ["***បន្ទាប់ពីបានទទួលការណែនាំបន្តបន្ទាប់ពីអង្គការ*** អំពីការយកចិត្តទុកដាក់ចំពោះខ្មាំង និងការបោសសម្អាត ***មន្ត្រីខ្មាំង*** យើងបានតាមដាន ពិនិត្យ និងរកឃើញមនុស្សដូចតទៅ..."]។ **E1/296.1** ប្រតិចារឹក, ៤ ឧសភា ២០១៥, ខឹម បឿន, ត្រង់ 11.20.25 ដល់ 11.22.40 ["សួរ: តើលោកស្រីមានចាំដែរទេ ថាមានមតិណែនាំពីថ្នាក់លើអំពីខ្មាំង និងការបោសសម្អាតទាហានខ្មាំង ជាពិសេសយោធា ហើយនឹងមន្ត្រីរដ្ឋការលន់ នល់ ដែលមានបណ្ដាសក្តិខ្ពស់ ដែរឬទេ? ឆ្លើយ: ចាសមាន"]។ **E3/2048** សេចក្តីរាយការណ៍ពីប្រធានឃុំ តាផេម គិត ផ្ញើជូនអង្គការ, ២៨ មេសា ១៩៧៧, ត្រង់ ERN ជាភាសាខ្មែរ 00079091, ត្រង់ ERN ជាភាសាអង់គ្លេស 00276564, ត្រង់ ERN ជាភាសាបារាំង 00611661 [សេចក្តីរាយការណ៍ថា ឃុំបានពិនិត្យ និងបោសសម្អាត***ខ្មាំងដែលមានបណ្ដាសក្តិ ក្រោយពីបានទទួលនូវមតិណែនាំរបស់បក្ស***"]។ ឯកសារ **E3/2435** សេចក្តីរាយការណ៍ពីឃុំអង្គតាសោម ជូនអង្គការស្រុក, ២៦ មេសា ១៩៧៧ ["អ្នកមាន***បណ្ដាសក្តិពីរ ឬមួយ*** យើងខ្ញុំទាក់ទងមិត្ត យន - យ/ធ ស្រុក យកល្ងាចនេះហើយ។"]

[16]សូមមើល ឧបសម្ព័ន្ធ ខ សម្ងាត់, លេខ ១៩-២៧។

[17] **D313/1.2.16** របាយការណ៍ Henri Locard មានចំណងជើងថា "ស្រុកត្រាំកក់ស្ថិតក្នុងកណ្ដាប់ដៃរបស់ខ្មែរក្រហម" ត្រង់ ERN ជាភាសាខ្មែរ 00739044, ជាភាសាអង់គ្លេស 00217700-01, ជាភាសាបារាំង 00743759-60 ["ក្នុងចំណោមអ្នកទោសជាប់ឃុំឃាំងទាំងនេះ ដែលមានចំនួន ៤៧៧នាក់ គេអាចកំណត់ថាមាន អតីតទាហាន ២២៥នាក់ ប្រពន្ធ១៥នាក់ (ក្នុងនោះម្នាក់ត្រូវបានកំណត់អត្តសញ្ញាណថាមានដើមកំណើតជាជនជាតិវៀតណាម) និង ៦នាក់ជាកុមារ។ ប្រសិនបើគេបូកបញ្ចូល អតីតនគរបាល ឬតម្រួតយោធា ២៧នាក់ទៀត នោះនឹងមានជនរងគ្រោះចំនួន ២៧៣នាក់ ជាប់ពាក់ព័ន្ធនឹងកងកម្លាំងសណ្ដាប់ធ្នាប់របស់របបមុន។"]។ **E3/4095** សៀវភៅគុកក្រាំងតាចាន់ ខែឧសភា ឆ្នាំ១៩៧៦ [កំណត់អត្តសញ្ញាណអ្នកទោស ១០៥ ដែល ៦២នាក់ ជាអតីតនាយទាហាន, ទាហាន, មន្ត្រីរដ្ឋការ, ប៉ូលិស, សាច់ញាត្តិ នៃរបប លន់ នល់ ឬបុគ្គលដែលមានទំនាក់ទំនងជាមួយនឹងរបប លន់ នល់]។

11. សក្ខីកម្មរបស់ ពេជ្រ ជឹម ផ្សេងទៀតដែលផ្តល់ដោយមេធាវីការពារក្តី ដែលពាក់ព័ន្ធនឹងការបកស្រាយខុសគ្នានៃពាក្យខ្មែរ *កម្ចាត់* មិនអាចជួយដល់មេធាវីការពារក្តីបានឡើយ។ នៅក្នុងអំឡុងនៃសវនាការ និងនៅក្នុងបណ្តឹងសាទុក្ខនេះ នួន ជា បានអះអាងថា *កម្ចាត់* មានន័យថា "ពង្រាយ ឬធ្វើឲ្យខ្ចាត់ខ្ចាយ"។ នៅក្នុងសវនាការ Steve Heder បានប្រកែកនឹងការបកស្រាយនេះ និងបានផ្តល់សក្ខីកម្មថា តាមពិតពាក្យនេះមានន័យគំរាមកំហែងច្រើនជាង ដែលមានន័យថា "ធ្វើឲ្យលែងមាន, ធ្វើឲ្យបាត់"[18]។ ពេជ្រ ជឹម បកស្រាយពាក្យនេះថាមានន័យ "យកចេញ ឬដកចេញ" ឬ "ធ្វើឲ្យលែងមាន"[19] ដែលជាការបកស្រាយស្របគ្នានឹងការបកស្រាយរបស់ Heder ដែរ ដែលផ្ទុយពីការបកស្រាយរបស់មេធាវីការពារក្តីដែលបានបញ្ជូននៅក្នុងបណ្តឹងសាទុក្ខនេះ។ មានពាក្យជាច្រើនមានអត្ថន័យខុសៗគ្នាទៅតាមបរិបទរបស់វា។ ការអះអាងរបស់ ពេជ្រ ជឹម នៅក្នុងការឆ្លើយតបទៅនឹងសំណួរនាំមុខពីមេធាវីការពារក្តីថា *កម្ចាត់* "អាចមានន័យផ្សេង" ពេលណាប្រើនៅក្នុងបរិបទនៃការកសាងខ្លួន ដែលមានការពាក់ព័ន្ធតិចតួច។ គាត់បានធ្វើការអះអាងដូចគ្នាបះបិទទៅនឹងពាក្យ *កម្ទេច* ដែលពីដើមដំបូងត្រូវបានអះអាងថា ពាក្យនេះមានន័យស្មើនឹង "បំបាត់ជំហាវណ្ណៈ" និង "ជម្រុះចោលពីក្នុងអារម្មណ៍ខួរក្បាល" ប៉ុន្តែយល់ស្របថា នៅពេលប្រើជាមួយខ្លាំងដែលជាប់ឃុំឃាំង គឺមានន័យថា "សម្លាប់"[20]។ ទោះក្នុងករណីណាក៏ដោយ ទស្សនៈយល់ឃើញរបស់សាក្សីម្នាក់អំពីភាពខុសគ្នាបន្តិចបន្តួចនៃពាក្យមួយ គឺមិនមែនជាប្រភេទនៃភស្តុតាងដែលអាច "ជាកត្តាកំណត់" នៅក្នុងសាលក្រមឡើយ។

## III. ដើម្បីកំណត់ថាតើសក្ខីកម្មរបស់ ពេជ្រ ជឹម និងរបស់សាក្សី SCW-4 ដែលបានផ្តល់ឲ្យគួរត្រូវបានទទួលយក ហើយទម្ងន់នៃកំណត់ហេតុទាំងនេះសមនឹងទទួលក្នុងព្រឹត្តិការណ៍ដូច្នេះដែរឬទេ ជាប្រយោជន៍នៃយុត្តិធម៌ដែលតម្រូវឲ្យអង្គជំនុំជម្រះនេះពិចារណាផងដែរលើភស្តុតាងថ្មីពីសវនាការនៃសំណុំរឿង០០២/០២ និងកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង០០៤ដែលគាំទ្រចំពោះសាលក្រម

[18] **E1/224.1** ប្រតិចារឹក, ១៦ កក្កដា ២០១៣, Stephen Heder, 15.15.32 ដល់ 15.19.30។

[19] **E1/291.1** ប្រតិចារឹក, ២៣ មេសា ២០១៥, ពេជ្រ ជឹម, ត្រង់ 14.40.11។

[20] **E1/290.1** ប្រតិចារឹក, ២២ មេសា ២០១៥, ពេជ្រ ជឹម, ត្រង់ 14.05.50 ដល់ 14.10.07។

12. ជាការបន្ថែមទៅលើសំណើសុំភ័ស្តុតាងបន្ថែមលើកទីបួននេះ នួន ជា បានដាក់រួចហើយនូវសំណើលើកទីប្រាំ ហើយបានលើកបញ្ជាក់ថា គាត់មានចេតនាដាក់សំណើដូច្នេះបន្ថែមទៀត[21]។ មេធាវីការពារក្តីគឺត្រូវ ដែលថាសវនាការដែលកំពុងធ្វើក្នុងសំណុំរឿង០០២/០២ និងកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង០០៤ នឹងបន្តបញ្ចេញលទ្ធផលនូវភ័ស្តុតាងថ្មីៗដែលពាក់ព័ន្ធនឹងការកំណត់គោលដៅអតីតទាហាន និងមន្ត្រី លន់ នល់ និងបញ្ហាផ្សេងៗទៀតក្នុងរយៈពេលនៅសល់ក្នុងឆ្នាំ២០១៥ និងឆ្នាំ២០១៦[22]។ ឥឡូវនេះ អង្គជំនុំជម្រះនេះកំពុងតែប្រឈមមុខដោយផ្ទាល់ជាមួយនឹងទស្សនីយភាពនៃសំណើគ្មានទីបញ្ចប់ពីម្ចាស់បណ្តឹងសាទុក្ខនានាដែលស្នើឲ្យស្តាប់ ឬទទួលយកភ័ស្តុតាងថ្មីដែលគំរាមកំហែងដល់ការពន្យារកិច្ចដំណើរការនីតិវិធីទាំងនេះជាច្រើនឆ្នាំ។

13. នៅតែជាទស្សនៈរបស់សហព្រះរាជអាជ្ញាដែលថា គ្មានកំណត់ហេតុស្តាប់ចម្លើយសាក្សី ឬភ័ស្តុតាងថ្មីដទៃទៀតណាមួយដែល នួន ជា បានស្នើសុំឲ្យទទួលយកជាភ័ស្តុតាងក្នុងសំណើមុនៗរបស់គាត់ដែលបានដាក់តាំងពីពេលចាប់ផ្តើមនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ បានបំពេញបទដ្ឋានកម្រិតខ្ពស់ដែលត្រូវអនុវត្តចំពោះការទទួលយកភ័ស្តុតាងថ្មីឡើយ - មានន័យថា ភ័ស្តុតាងដែលមានទម្ងន់រហូតដល់អាចធ្វើជា "កត្តាកំណត់" ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងយកទៅពិចារណានាំដល់សាលក្រមរបស់ខ្លួន។

14. តាមការពង្រីកនេះ អង្គជំនុំជម្រះមានបំណងបើកឡើងវិញនូវភ័ស្តុតាងអំពីបញ្ហាដូចជា គោលនយោបាយរបស់ បកក ចំពោះអតីតមន្ត្រីរដ្ឋការ និងទាហាន លន់ នល់ ជាដើម នោះសហព្រះរាអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះមិនអាចត្រូវបានកម្រិតត្រឹមតែកំណត់ហេតុដាច់ឆ្ងាយពីគេ ដែលមេធាវីការពារក្តីជឿថា មានលក្ខណៈអនុគ្រោះចំពោះខ្លួនដែលពួកខ្លួនបានជ្រើសរើសដោយចោះៗ ចេញពីកំណត់ហេតុស្តាប់ចម្លើយសាក្សីរាប់រយនៃសំណុំរឿង០០៣ និង០០៤ និងសក្ខីកម្មសាក្សីសវនាការថ្មីនៃសំណុំរឿង០០២/០២ រាប់រយម៉ោងនោះឡើយ។ ប្រសិនបើភ័ស្តុតាងកំពុងបើកឡើងវិញលើបញ្ហានេះមែន នោះជាប្រយោជន៍នៃយុត្តិធម៌ និងជាសារៈសំខាន់សម្រាប់បញ្ជាក់អំពីការពិត អង្គជំនុំជម្រះក៏ទទួលយក និងពិចារណាលើភាពសំបូរបែបនៃភ័ស្តុតាងពីសំណុំរឿង០០២ ០០៣ និង០០៤

[21] **F2/6** សំណើលើកទីបួនរបស់ នួន ជា ស្នើសុំឲ្យពិចារណាលើភ័ស្តុតាងបន្ថែម, កថាខណ្ឌ៤ [មេធាវីការពារក្តីនឹងដាក់ភ័ស្តុតាងបន្ថែមជូនអង្គជំនុំជម្រះតុលាការកំពូល នៅពេលណាខ្លួនបានដឹងអំពីភ័ស្តុតាងពាក់ព័ន្ធបន្ថែមទៀត ក្នុងសំណុំរឿង០០២/០២]។

[22] **F2/6** សំណើលើកទីបួនរបស់ នួន ជា ស្នើសុំឲ្យពិចារណាលើភ័ស្តុតាងបន្ថែម, កថាខណ្ឌ៤-៥។

ដែលគាំទ្រដល់ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីអំពីគោលនយោបាយកំណត់គោលដៅចំពោះមន្ត្រី និងទាហាន លន់ នល់ ផងដែរ។

15. **ឧបសម្ព័ន្ធ ក** ដែលបានដាក់ជូនទៅជាមួយចម្លើយតបនេះ កំណត់អត្តសញ្ញាណសក្ខីកម្មសវនាការសំណុំរឿង០០២/០២ ចំនួន២៤ថ្ងៃ ពីសាក្សីយ៉ាងហោចណាស់១៨នាក់ ដែលគាំទ្រអត្ថិភាពនៃគោលនយោបាយបោសសម្អាត និងសម្លាប់មន្ត្រី និងទាហានលន់ នល់ នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងចិរវេលាភ្លាមៗ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ **ឧបសម្ព័ន្ធ ខ** កំណត់អត្តសញ្ញាកំណត់ហេតុស្តាប់ចម្លើយសាក្សីថ្មីចំនួន៩៧ ពីសំណុំរឿង០០៣ និង០០៤ ដែលក៏បានផ្តល់សក្ខីកម្មអំពីអត្ថិភាពគោលនយោបាយនោះដែរ[23]។ នៅពេលពិនិត្យមើលទាំងស្រុងឃើញថា ភ័ស្តុតាងថ្មីពីសវនាការ និងកិច្ចស៊ើបសួរដែលកំពុងបន្តធ្វើ គាំទ្រយ៉ាងលើសលប់ចំពោះសាលក្រម ហើយភ័ស្តុតាងមានកំណត់មួយចំនួន ដែលបានជ្រើសរើសដោយមេធាវីការពារក្តីពីសំណុំរឿងទាំងនោះ មិនបានបំពេញលក្ខណវិនិច្ឆ័យនៃវិធាន១០៨(៧) នៃវិធានផ្ទៃក្នុង ឬផ្តល់នូវមូលដ្ឋានធម្មានុរូបណាមួយ ដើម្បីឲ្យមានការកែប្រែការកាត់ទោសក្នុងសំណុំរឿង០០២/០១ ឡើយ៕

## IV. សេចក្តីសន្និដ្ឋាន

16. ដូចមូលហេតុដែលបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលសំណើរបស់មេធាវីការពារក្តី នួន ជា សុំឲ្យទទួលយកសក្ខីកម្មរបស់ ពេជ្រ ជឹម ពីសំណុំរឿង០០២/០២។ ប៉ុន្តែ បើសិនជាអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សមរម្យដែលត្រូវទទួលយកសក្ខីកម្មរបស់ ពេជ្រ ជឹម ឬភ័ស្តុតាងថ្មីណាមួយផ្សេងទៀតទាក់ទងនឹងគោលនយោបាយ បកក ចំពោះទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើ

---

[23] ឧបសម្ព័ន្ធនេះចុះបញ្ជីទាំងកាលបរិច្ឆេទដែលសាក្សីត្រូវបានស្តាប់ចម្លើយ និងខែដែល កសចស បានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយទៅក្នុងសំណុំរឿង០០២។ ការងារដែលសហព្រះរាជអាជ្ញាដាក់បង្ហាញកំណត់ហេតុនោះហើយដែលពាក់ព័ន្ធនឹងការកំណត់ថាតើភ័ស្តុតាងនេះមិនអាចរកបាននៅក្នុងអំឡុងពេលសវនាការ។ ដូចបានកត់សម្គាល់នៅក្នុងការដាក់ឯកសារមុនៗដែលរាប់រៀបអំពីប្រវត្តិសាវតារនៃការដាក់បង្ហាញឯកសារទាំងនេះ សហចៅក្រមស៊ើបអង្កេតបានច្រានចោលសំណើសុំលើកដំបូងរបស់ កសព ដើម្បីដាក់បង្ហាញសម្ភារៈទាំងនេះ និងបានពន្យារការអនុញ្ញាតដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីភាគច្រើននៃសំណុំរឿង០០៣ និង០០៤រហូតដល់ឆ្នាំ២០១៥ អាស្រ័យដោយសារការព្រួយបារម្ភអំពីការសម្ងាត់នៃកិច្ចស៊ើបសួរ។

ឲ្យអង្គជំនុំនេះទទួលយកជាភ័ស្តុតាងថ្មីដែលបង្ហាញបន្ថែមពីគោលនយោបាយនៅក្រោមលក្ខណៈវិនិច្ឆ័យដូចគ្នានេះផងដែរ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | |